# ធនាគារពិភពលោក

## ការិយាល័យកម្ពុជា

**ទាក់ទង:** *នៅភ្នំពេញៈប៊ូ សារឿន.* 855-23-213-538
sbou@worldbank.org

## ធនាគារពិភពលោកនឹងផ្សព្វផ្សាយការពិនិត្យមើលថ្មីៗបំផុតស្តីអំពីសេដ្ឋកិច្ចនៅកម្ពុជា និងនៅតំបន់ នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០០៧

### *របាយការណ៍នឹងបង្ហាញអោយឃើញអំពីសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីបូព៌ារយៈពេល ១០ ឆ្នាំ បន្ទាប់ពីវិបត្តិសេដ្ឋកិច្ចដែលបានយាយីតំបន់នេះកន្លងមក*

ការពិនិត្យមើលថ្មីៗបំផុតរបស់ធនាគារពិភពលោកចំពោះសេដ្ឋកិច្ចកម្ពុជា និងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលមានចំណងជើងថា "បច្ចុប្បន្នភាពនៃតំបន់អាស៊ីបូព៌ា" នឹងត្រូវផ្សព្វផ្សាយនៅថ្ងៃព្រហស្បត្តិ៍ ទី ៥ ខែ មេសា ឆ្នាំ ២០០៧។ ឯកសារនេះអាចរកបានតាមរយៈវេបសាយរបស់មណ្ឌលព័ត៌មានសំរាប់អ្នកសារព័ត៌មានរបស់ធនាគារពិភពលោក (OMBC) ។

បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុឆ្នាំ ១៩៩៧ - ៩៨ អស់រយៈពេល ១០ ឆ្នាំមក ពេលនេះ តំបន់នេះមានលុយច្រើន មានចំនួនអ្នកក្រីក្រថយចុះ និងបានដើរតួយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចសកលដែលមិនធ្លាប់មានពីមុនមក ។ ដោយសារកំណើនចេះតែបន្តសំរាប់ប្រទេសចិន ដែលជាប្រទេសងើបឡើងនៅក្នុងសេដ្ឋកិច្ចអាស៊ីបូព៌ា ពេលនេះតំលៃកំណើនផលិតផលក្នុងស្រុក បានកើនឡើងចំនួនទ្វេដងនៃតំលៃដុល្លា នារយៈពេលមួយទសវត្សរ៍កន្លងមកនេះ ។ ភាពក្រីក្រ កំពុងតែធ្លាក់ចុះយ៉ាងច្រើន គឺច្រើនជាងមុនពេលដែលប្រទេសនៅអាស៊ីបូព៌ាមានវិបត្តិសេដ្ឋកិច្ចទៅទៀត ។ ប៉ុន្តែទន្ទឹមនឹងពេលដែលប្រទេសទាំងនេះមានភាពត្រេកអរនឹងកំណើននេះ ក៏នៅមានបញ្ហាប្រឈមនានាដែលវានឹងអាចបន្ថចបង្អាក់ ឬរារាំងកំណើនប្រសិនបើបញ្ហាទាំងនោះមិនត្រូវបានដោះស្រាយអោយបានត្រឹមត្រូវនោះទេ ប្រទេសនៅអាស៊ីបូព៌ានឹងអាចរកឃើញថា ខ្លួនឯងស្ថិតនៅក្នុងអន្ទាក់មួយនៃប្រទេសដែលមានចំណូលមធ្យម ហើយប្រឈមទៅនឹងការឈានឡើងដោយសន្សឹមៗ ទៅរកប្រទេសដែលមានចំណូលខ្ពស់ ។

លើសពីនេះការសំឡឹងមើលសំរាប់សេដ្ឋកិច្ចកម្ពុជា ក៏នឹងត្រូវបានពិភាក្សាផងដែរនៅក្នុងរបាយការណ៍បច្ចុប្បន្នភាពដោយផ្តោតសំខាន់ទៅលើការអភិវឌ្ឍទីក្រុង ។

ការសង្ខេបមួយស្តីអំពីការរកឃើញសំរាប់របាយការណ៍នេះ នឹងធ្វើឡើងនៅការិយាល័យធនាគារពិភពលោក អាសយដ្ឋានផ្ទះលេខ ១១៣ មហាវិថីព្រះនរោត្តម នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០០៧ ចាប់ផ្តើមពីម៉ោង ៩ ដល់ម៉ោង ១០:៣០ នាទីព្រឹក ។ លោក មីលែន ប្រាមបាត អ្នកសេដ្ឋកិច្ចជាន់ខ្ពស់ប្រចាំតំបន់ នឹងពិភាក្សាអំពីការប្រមើលមើលសំរាប់សេដ្ឋកិច្ចនៅកម្ពុជា និងនៅបណ្តាប្រទេសនានានៅក្នុងតំបន់តាមរយៈប្រព័ន្ធវីដេអូទំនើប ពីទីក្រុងតូក្យូប្រទេសជប៉ុន ។ លោកស្រី នីសា អាក្រាវ៉ាល ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា លោក ជា ហួត អ្នកសេដ្ឋកិច្ច ព្រមទាំងអ្នកឯកទេសសេដ្ឋកិច្ចកម្ពុជាជាច្រើននាក់ទៀតនឹងចូលរួមពិភាក្សាសំរាប់សេដ្ឋកិច្ចកម្ពុជា ។

បច្ចុប្បន្នភាពនៃតំបន់អាស៊ីបូពា និងប៉ាស៊ីហ្វិក គឺជាការពិនិត្យមើលដ៏សំខាន់របស់ធនាគារពិភពលោកចំពោះសេដ្ឋកិច្ចរបស់តំបន់នេះ ។ ការពិនិត្យមើលនេះចេញផ្សព្វផ្សាយ ពីរដងក្នុងមួយឆ្នាំ ហើយអាចរកបានដោយសេរីនៅក្នុងវេបសាយរបស់យើង គឺ http://www.worldbank.org/eapupdate បន្ទាប់ពីការហាមឃាត់មិន អោយផ្សព្វផ្សាយត្រូវបានលើកចេញ។

សូមឆ្លើយតបចំពោះការចូលរួមបានរបស់លោកនៅក្នុងការផ្សព្វផ្សាយនេះ ទៅ លោក ប៊ូ សារឿន តាមរយៈអ៊ីម៉ែលរបស់គាត់គឺ sbou@worldbank.org. សន្និសីទនេះធ្វើឡើងជាភាសាអង់គ្លេស ប៉ុន្តែមានឯកសារមួយចំនួនបកប្រែជាភាសាខ្មែរផងដែរ ។

###

ឯកសារនឹងអាចរកបានមុនពេលផ្សព្វផ្សាយសំរាប់អ្នកកាសែតតាមរយៈមជ្ឈមណ្ឌលផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធអ៊ីនធើណែត ។ អ្នកកាសែតដែលបានចុះឈ្មោះហើយនឹងទទួលបានព័ត៌មាននោះជាស្វ័យប្រវត្តិ ។ ដើម្បីចុះឈ្មោះសូមចុចទៅវេបសាយខាងក្រោមនេះ *http://media.worldbank.org/*